# អត្ថន័យផ្នែកនយោបាយនៃផ្តែរទ្វារស.វ.ទី៧

ជាទូទៅកាលណាគេនិយាយអំពីផ្តែរទ្វារស.វ.ទី៧ គឺគេតែងសំដៅលើរចនាបថសិល្បៈចំនួន២ពោល គឺរចនាបថសំបូរព្រៃគុក (គ.ស.៦០០-៦៥០) និងរចនាបថព្រៃក្មេង (គ.ស.៦៣៥-៧០០)។ នៅសម័យដំបូងៗ ដូចឃើញនៅតំបន់ប្រាសាទថាឡាបរិវ៉ាត់ ផ្តែរទ្វារភាគច្រើនយើងតែងឃើញមានរូបសត្វមករធំៗនៅសងខាង និងមានក្បាច់ដងផ្ចូ (ឥណ្ឌាហៅថា "តោរណ") កោងចូលគ្នាបង្កើតបានជាចំណុចប្រសព្វនៅចំកណ្តាលមួយ។ តោរណ បែបនេះមានលក្ខណៈដូចនៅស្រុកឥណ្ឌាខ្លាំងណាស់។ ប៉ុន្តែក្រោយមក ក្បាច់តោរណក៏បានវិវឌ្ឍន៍ទៅជារបៀបថ្មីមួយទៀតតាមរបៀបជាសិល្បៈច្នៃប្រឌិតថ្មីនៅក្នុងស្រុក ដោយយើងឃើញមានក្បាច់កំណាត់ដងផ្ចូកោងខ្ញីៗបង្កើតបានជាចំណុចប្រសព្វចំនួន៣ ដែលក្នុងនោះគេតែងសង្កេតឃើញថា ពេលខ្លះមានរូបព្រះឥន្ទ្រគង់នៅលើដំរីនៅចំកណ្តាល អមដោយរូបទេពជិះសេះ (មរុត) ចំនួនពីរទៀតនៅអមសងខាង។ "ព្រះឥន្ទ្រ" គឺជាស្តេចនៅស្ថានសួគ៌ រីឯ "មរុត" គឺជាទ័ពខ្យល់របស់ព្រះឥន្ទ្រនៅស្ថានសួគ៌។ ផ្តែរទ្វារដែលមានរូបព្រះឥន្ទ្រនៅកណ្តាល អមដោយមរុតនៅសងខាងនេះ គេឃើញមានប្រហែល ៣០ ផ្ទាំង រាយប៉ាយនៅទូទាំងប្រទេសកម្ពុជា និងមាននៅទឹកដីសៀមបច្ចុប្បន្នផង។ តើផ្តែរទ្វារមានរូបព្រះឥន្ទ្រ និងមរុត នៅស.វ.ទី៧ មានអត្ថន័យពាក់ព័ន្ធនឹងនយោបាយរបស់ព្រះមហាក្សត្រនាសម័យនោះយ៉ាងដូចម្តេចខ្លះ?

ប្រសិនបើគិតអំពីព្រះមហាក្សត្រចន្លោះពីគ.ស. ៦០០ ដល់ ៧០០ យ៉ាងហោចណាស់ក៏មានចំនួន ៥អង្គដែរ រួមមាន ព្រះបាទភវវរ្ម័នទី១ ព្រះបាទមហេន្ទ្រវរ្ម័ន ព្រះបាទឦសានវរ្ម័នទី១ ព្រះបាទភវវរ្ម័នទី២ និងព្រះបាទជ័យវរ្ម័នទី១។ ក្នុងចំណោមព្រះមហាក្សត្រទាំង ៥អង្គនេះ ព្រះបាទឦសានវរ្ម័នទី១ និងព្រះបាទជ័យវរ្ម័នទី១ ហាក់មានព្រឹត្តិការណ៍នយោបាយគួរកត់សម្គាល់ច្រើនជាងព្រះមហាក្សត្រអង្គផ្សេងទៀត។ តាមព័ត៌មានអំពីសិលាចារឹកនៅស.វ.ទី៧ យើងតែងឃើញគេច្រើនប្រៀបអំណាចព្រះរាជាដែលជាអ្នកគ្រប់គ្រងនៅរាជធានីឦសានបុរ (សំបូរព្រៃគុក) ប្រដូចទៅនឹងព្រះឥន្ទ្រ ពោល គឺមានន័យថា ស្តេចនៅលើផែនដី ហាក់មានអំណាចខ្លាំងក្លាដូចព្រះឥន្ទ្រដែលជាស្តេចនៅស្ថានសួគ៌ដូច្នោះដែរ។ ជាឧទាហរណ៍ សិលាចារឹកប្រាសាទអុក និងក្លោងទ្វារខាងកើតក្រុមប្រាសាទយាយព័ន្ធ K.440 និង K.442 រៀបរាប់ថា៖ *"ព្រះបាទឦសានវរ្ម័នទី១ អន្ទះសាចង់បានស្ថានសួគ៌ និងដំរីរបស់ព្រះឥន្ទ្រ"*[៩]។ សិលាចារឹកមួយទៀតនៅក្រុមប្រាសាទយាយ

[៩] Coedès 1952: 5-14.

ព័ន្ធដដែល តួប៉ម S17-17 ចុះបញ្ជីលេខ K.604 រៀបរាប់ថា៖ "ព្រះបាទឦសានវរ្ម័នទី១ មានឫទ្ធានុភាពអស្ចារ្យលើសទេពដែលកាន់វជ្រ (ព្រះឥន្ទ្រ) ទៅទៀត"[២]។ រីឯសិលាចារឹកមួយទៀតនៅប្រាសាទស្រីគ្រប់ល័ក្ខណ (សំបូរព្រៃគុក) ចុះបញ្ជីលេខ K.151 ក៏រៀបរាប់ថា៖ "នរសិង្ហគុប្តដែលទំនងជាស្តេចត្រាញ់បម្រើឱ្យព្រះបាទឦសានវរ្ម័នទី១ បានពោលសរសើរព្រះបាទឦសានវរ្ម័នទី១ ជាស្តេចប្រកបដោយគុណធម៌ អង់អាចហានក្លាលើសសត្រូវផងនានា ប្រៀបបាននឹងព្រះឥន្ទ្រដែលជាស្តេចនៃទេព"[៣]។ នៅឆ្ងាយពីតំបន់ឦសានបុរ (សំបូរព្រៃគុក) ក៏មានសិលាចារឹកផ្សេងទៀតដែលរៀបរាប់អំពីស្តេចនិងព្រះឥន្ទ្រដែរ។ ជាក់ស្តែង សិលាចារឹកប្រាសាទត្រោតាសរ នៅស្រុកបាទី ខេត្តតាកែវ ចុះបញ្ជីលេខ K.709 រៀបរាប់ថា៖ "ព្រះបាទឦសានវរ្ម័នទី១ បានបរិច្ចាកស្រែមួយ គោក្របី ៦០ក្បាល ដែលដីខ្វះមានអំណាចស្មើនឹងព្រះឥន្ទ្រ"[៤]។ ក្រៅពីនេះទៀត គេដឹងថាទីក្រុងមួយរបស់ព្រះបាទជ័យវរ្ម័នទី១ ឈ្មោះថា "បុរន្ទរបុរ" ប្រែថា "ទីក្រុងនៃព្រះឥន្ទ្រ"[៥]។ ដោយឡែក សម្រាប់មរុតវិញ មានសិលាចារឹកមួយនៅស.វ.ទី៧ ចុះបញ្ជីលេខ K.81 រកឃើញនៅភ្នំហាន់ជ័យ ខេត្តកំពង់ចាម គេបានប្រៀបប្រដូចព្រះរាជាមានតេជៈបារមី ភ្លឺថ្លា ប្រៀបដូចព្រះកុមារ ដែលដឹកនាំកងទ័ពមរុតនៅស្ថានព្រះឥន្ទ្រ។[៦] ត្រង់ចំណុចនេះ មានន័យថា ចម្លាក់ព្រះឥន្ទ្រ សំដៅទៅលើអ្នកគ្រប់គ្រងនគរ (ព្រះរាជា) រីឯចម្លាក់មរុតសំដៅទៅលើកងយោធា ទឹកដី ឬអ្នកនៅក្រោមអំណាចរបស់ព្រះរាជា។

សិលាចារឹកខាងលើជាប្រភពដែលអាចគាំទ្រថា ផ្ដែរទ្វារនៅស.វ.ទី៧ ដែលមានរូបចម្លាក់ព្រះឥន្ទ្រគង់នៅលើដំរី អមដោយព្រះមរុតជិះលើសេះ អាចមិនត្រឹមតែជាក្បាច់លម្អរបស់ប្រាសាទ ឬទាក់ទងនឹងគំនិតពិធីសាសនាប៉ុណ្ណោះទេ។ ប៉ុន្តែ លោក Ben Wreyford យល់ថា ចម្លាក់ព្រះឥន្ទ្រ និងមរុត ទំនងដើរតួនាទីជាសិល្បៈក្នុងការផ្សព្វផ្សាយអំណាច និងទឹកដីរបស់ព្រះរាជានៅស.វ.ទី៧ ព្រោះអំណាចរបស់ស្តេចផែនដីគេប្រៀបប្រដូចទៅនឹងអំណាចរបស់ព្រះឥន្ទ្រដែលជាស្តេច នៃទេព។[៧] ដូចមានភស្តុតាងស្រាប់ ផ្ដែរទ្វារស.វ.ទី៧រូបព្រះឥន្ទ្រនិងមរុត គេមិនឃើញត្រឹមតែនៅរាជធានីឦសានបុរ (សំបូរព្រៃគុក) ដែលជាតំបន់រដ្ឋបាលសំខាន់របស់ព្រះបាទឦសានវរ្ម័នទី១ ប៉ុណ្ណោះទេ (រូបលេខ១-២) ប៉ុន្តែគេឃើញសាយភាយជាច្រើនកន្លែងនៅទូទាំងប្រទេស។ ឧទាហរណ៍ ផ្ដែរទ្វារ

[២] Finot 1915. Coedès 1952: 17-19.

[៣] Coedès 1943: 7.

[៤] Coedès 1953: 30-31.

[៥] Vickery 1998: 352-356.

[៦] Barth 1885.

[៧] Ben 2018: 155-160.

ព្រះឥន្ទ្រ និងមរុត ស.វ.ទី៧ រកឃើញនៅទីតាំងបុរាណដ្ឋានជាច្រើននៅខេត្តកំពង់ធំ និងកំពង់ចាម ដែលជាទឹកដីស្ថិតនៅមិនឆ្ងាយពីសំបូរព្រៃគុក ដូចជា ព្រះធាតុរកា (រូបលេខ២៣) វត្តបឹងខាងត្បូង (រូបលេខ២៤) ភ្នំជើងព្រៃ (រូបលេខ២៥) វត្តសូភាស (រូបលេខ២៦) ប្រាសាទដំបងដែក (រូបលេខ២៧) ។ល។ តំបន់ទាំងនេះ សុទ្ធសឹងតែជាតំបន់ដែលមានជាប់ទាក់ទងនឹងព្រឹត្តិការណ៍នយោបាយរបស់ព្រះបាទឦសានវរ្ម័នទី១ និងស្តេចក្រោយរាជ្យរបស់ទ្រង់មួយចំនួនទៀត។

ជាងនេះទៅទៀត ប្រសិនយើងមើលទៅភាគខាងត្បូងប្រទេសវិញ ជាពិសេស ទឹកដីនៅក្បែរៗរាជធានីភ្នំពេញសព្វថ្ងៃ យើងឃើញមានផ្តែរទ្វារមួយចំនួនរចនាឡើងជារូបព្រះឥន្ទ្រគង់នៅលើដំរីអមដោយមរុតជិះលើសេះដូចគ្នា។ ឧទាហរណ៍ ផ្តែរទ្វារវត្តខ្សល់ និងផ្តែរទ្វារវត្តភូមិថ្មី (សព្វថ្ងៃបាត់ទៅហើយ) គេឃើញមានក្បាច់ស្លឹកឈើមានការវិវឌ្ឍខ្លាំងខុសពីក្បាច់ដែលឃើញនៅរចនាបថសំបូរព្រៃគុក និងព្រៃក្មេង ប៉ុន្តែវាក៏មិនដូចក្បាច់ស្លឹកឈើនៅផ្តែររចនាបថកំពង់ព្រះដូចគ្នា (រូបលេខ២៨)។ ប៉ុន្តែ បើយោងតាមភស្តុតាងជាសិលាចារឹកដែលនៅរកឃើញនៅទីនោះដូចជា K.78 បញ្ជាក់ថា ស្ថិតនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១ នៅក្នុងគ.ស.៦៦៨ និងឆ្នាំ ៦៧៧។[៨]

លើសពីនេះទៀត បើយើងហួសឆ្ងាយពីតំបន់ជុំវិញរាជធានីឦសានបុរ និងតំបន់ភាគខាងត្បូង យើងឃើញថានៅស្រុកសៀមបច្ចុប្បន្ន ត្រង់ភូមិសាស្ត្រក្បែរអារញ្ញប្រះថេត (Aranyaprathet) ភាគខាងកើតប្រទេសសៀម ក៏មានផ្តែរទ្វាររចនាបថសំបូរព្រៃគុក ឆ្លាក់រូបព្រះឥន្ទ្រ និងមរុតដែរ ជាក់ស្តែងដូចជា ផ្តែរទ្វារប្រាសាទខៅណាយ (រូបលេខ២៩)។ ភូមិសាស្ត្រនេះគេធ្លាប់រកឃើញសិលាចារឹក K.506 ដែលរៀបរាប់ឱ្យដឹងថា នៅគ.ស.ឆ្នាំ៦៣៧ ព្រះបាទឦសានវរ្ម័នទី១ បានតែងតាំងមន្ត្រីម្នាក់ឈ្មោះ "ឦស្វរកុមារ" ជាអភិបាលក្រុងជ្យេស្ឋបុរ[៩]។ រីឯសិលាចារឹកមួយទៀត រកឃើញនៅទីនោះដដែល ចុះបញ្ជីលេខ K.1150 មានអាយុកាលក្រោយសិលាចារឹក K.506 បន្តិច ក៏បានរៀបរាប់ថា "បុត្រារបស់ព្រះបាទឦសានវរ្ម័នទី១ ព្រះនាម "សិវទត្ត" ត្រូវបានតែងតាំងជាចៅហ្វាយក្រុងថ្មីនៅជ្យេស្ឋបុរ។[១០] ពត៌មានសិលាចារឹកទាំងពីរនេះ គឺជាប្រភពដ៏សំខាន់បញ្ជាក់ថា អំណាចព្រះរាជានៅឦសានបុរ មានឥទ្ធិពលធំធេងទៅលើទឹកដីឆ្ងាយពីរាជធានីកណ្តាលរបស់ចេនឡា ដែលស្ថិតនៅសំបូរព្រៃគុក ខេត្តកំពង់ធំ។ ក្នុងនោះ ផ្តែរទ្វាររូបព្រះឥន្ទ្រ និងមរុត ដើរតួនាទីសំខាន់ជាសិល្បៈដែលផ្សព្វផ្សាយអំពីអំណាច និងទឹកដីរបស់ព្រះរាជា។

---

[៨] Coedès 1954: 12-13; Vickery 1998: 119 & 350.

[៩] Vickery 1998: 129-130 & 338.

[១០] Vickery 1998: 198-199.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ការយករូបចម្លាក់ព្រះឥន្ទ្រ និងមរុតនៅលើផ្ដែរទ្វារ មកពិចារណាពាក់ព័ន្ធជាមួយនយោបាយនេះ វាដូចទៅនឹងការសន្និដ្ឋានរបស់លោក Paul Lavy ដែលយល់ថា រូបព្រះហរិហរ (វិស្ណុ-សិវ) នៅស.វ.ទី៧ ដល់ទី៩ មានមុខងារដើរតួនាទីតំណាងឱ្យភាពជាស្ដេច។ លោកយល់បែបនេះដោយហេតុផលថា ការផ្លាស់ប្ដូរនយោបាយពីតំបន់ខាងត្បូងមកខាងជើង នាំឱ្យសិទ្ធិផ្លាស់ប្ដូរនយោបាយគួរកត់សម្គាល់ ដូច្នេះលោកគិតថា ការប្រើប្រាស់រូបភាពព្រះហរិហរ គឺជាការបង្រួមអំណាចរវាងខាងត្បូងដែលគោរពនិកាយវៃស្ណវ (ព្រះវិស្ណុ ឬហរិ) និងខាងជើងដែលគោរពនិកាយសៃវ (ព្រះសិវ ឬហរ)[១១]។

ដូច្នេះជារួមមកផ្ដែរទ្វារនៅស.វ.ទី៧ ដែលមានចម្លាក់រូបព្រះឥន្ទ្រគង់នៅលើដំរីអៃរាវតដោយរូបព្រះមរុតគង់នៅលើសេះ ប្រហែលមិនមែនធ្លាក់ឡើងដើម្បីតែការលម្អរបស់ប្រាសាទ ឬគំនិតទាក់ទងនឹងសាសនាព្រាហ្មណ៍ប៉ុណ្ណោះទេ តែទំនងអាចបង្កប់ន័យនយោបាយ ក្នុងគំនិតដែលយកសិល្បៈជាយានក្នុងការផ្សព្វផ្សាយអំពីអំណាច និងទឹកដីរបស់អ្នកគ្រប់គ្រងប្រទេសនាស.វ.ទី៧ ជាពិសេស គឺព្រះបាទឦសានវរ្ម័នទី១ និងអ្នកស្នងរាជ្យបន្ទាប់របស់ទ្រង់។ ដូច្នេះ យើងឃើញថា អំណាចរបស់ព្រះបាទឦសានវរ្ម័នទី១ ដែលជាស្ដេចសោយរាជ្យនៅរាជធានីឦសានបុរ (សំបូរព្រៃគុក) មានវិសាលភាពអំណាច និងទឹកដីវែងឆ្ងាយពីរាជធានីកណ្ដាលខ្លាំងណាស់ មានន័យថា ទៅខាងត្បូងក៏មាន ទៅខាងជើងម្ដុំប្រទេសសព្វថ្ងៃក៏មាន៕

## ឯកសារយោង


**Barth, A.**

1885, *Inscription Sanskrities du Cambodge,* Paris.

**Ben, W.**

2018, *Seeing the 'Foreigner' In The Art of Early Southeast Asia c. 1000 BCE – c. 900 CE,* Thesis submitted for the degree of PhD, SOAS University of London.

**Coedès, G.**

- 1943: "Quelque précisions sur la fin du Fou-Nan" *BEFEO*, Tome 43, Paris.
- 1952, *Inscription du Cambodge*, Vol IV, Hanoi.
- 1953, *Inscription du Cambodge*, Vol V, Hanoi.
- 1954, *Inscription du Cambodge*, Vol VI, Hanoi.

**Finot, L.**

1915, Notes d'epigrahie, les inscription du musée de Hanoi, *BEFEO*, Tome 15, pp. 1-135.

**Lavy, P.A.**

2003, 'As in Heaven, So on Earth: The Politics of Viṣṇu, Śiva and Harihara Images in


[១១] Lavy 2003: 21-39.

Preangkorian Khmer Civilisation', *Journal of Southeast Asian Studies* 34, no. 1 (2003): 21–39.

**Vickery, M.**

1998, *Society, Economic and Politics in pre-Angkor Cambodia, 7th - 8th centuries*, Tokyo.



រូបលេខ១៖ ចម្លាក់ព្រះឥន្ទ្រ-មរុតឆ្លាក់លើផ្ដែរក្នុងតំបន់ប្រាសាទសំបូរព្រៃគុក (រូបថត៖ ឯម ភារក្ស)



រូបលេខ២៖ ចម្លាក់ព្រះឥន្ទ្រ-មរុតឆ្លាក់លើផ្ដែរក្នុងតំបន់ប្រាសាទសំបូរព្រៃគុក (រូបថត៖ លួន ទីឃា)



រូបលេខ៣៖ ចម្លាក់ព្រះឥន្ទ្រ-មរុតឆ្លាក់លើផ្ដែរប្រាសាទព្រះធាតុរកា ខេត្តកំពង់ធំ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៤៖ ចម្លាក់ព្រះឥន្ទ្រ-មរុតធ្លាក់លើផ្តែរប្រាសាទវត្តបឹងខាងត្បូង ខេត្តកំពង់ធំ



រូបលេខ២៥៖ ចម្លាក់ព្រះឥន្ទ្រ-មរុតធ្លាក់លើផ្តែរប្រាសាទភ្នំធំ ខេត្តកំពង់ចាម (រូបថត៖ ថៃ ឈាងម៉េង)



រូបលេខ២៦៖ ចម្លាក់ព្រះឥន្ទ្រ-មរុតធ្លាក់លើផ្តែរប្រាសាទវត្តសូភាស ខេត្តកំពង់ចាម

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៧៖ ចម្លាក់ព្រះឥន្ទ្រ-មរុតឆ្លាក់លើផ្តែរប្រាសាទដំបងដែក ខេត្តកំពង់ចាម



រូបលេខ៨៖ ចម្លាក់ព្រះឥន្ទ្រ-មរុតឆ្លាក់លើផ្តែរវត្តភូមិថ្មី រាជធានីភ្នំពេញ



រូបលេខ៩៖ ចម្លាក់ព្រះឥន្ទ្រ-មរុតឆ្លាក់លើផ្តែរប្រាសាទខោណាយ ប្រទេសថៃ

អត្ថបទដោយ៖ ម៉ង់ រ៉ាលី